ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ ឆ្នាំ២០២៤

ថ្ងៃអាទិត្យ ១កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨

ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៤

រៀបចំដោយៈ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ទ្វេបត្តម្ភដោយៈ ថវិកាជាតិ

១. សេចក្តីផ្តើម

នៅថ្ងៃអាទិត្យ ១កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៤ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជា នៅសាលសន្និសីតចតុមុខ។ នៅក្នុងពិធីប្រារព្ធទិវានេះ មានការចូលរួមពី ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មន្ត្រីអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍តាមក្រសួង ស្ថាប័ន និងសមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសក្រសួង ស្ថាប័ន កងកម្លាំងខេមរភូមិន្ទ កងនគរបាលជាតិ យុវជនកាកបាទក្រហមកម្ពុជា ក្រុមយុវជនស.ស.យ.ក សមាជិកកាយឫទ្ធិនារីកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អង្គការអន្តរជាតិ ក្រុមប្រជាជនគន្លឹះ បណ្តាញអ្នកផ្តុំកមេរោគអេដស៍ សរុបចំនួន៥០០នាក់។

២. កម្មវិធីនៃការប្រារព្ធទិវា

ការប្រារព្ធទិវាបានប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម៖

- សមាជិក សមាជិកាអញ្ជើញមកដល់ (ការចុះឈ្មោះអ្នកចូលរួម)
- ការអញ្ជើញដល់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**
- ប្រកាសហេតុ គោលបំណង និងរបៀបវារៈនៃការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍

- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ចំណាប់អារម្មណ៍របស់អ្នកស្រី ហាន សៀងហ៊ិន តំណាងអ្នកផ្តុកមេរោគអេដស៍
- ចំណាប់អារម្មណ៍របស់លោកវេជ្ជបណ្ឌិត សុខ ប៊ុន តំណាងប្រធានគណៈកម្មាធិការដើកនាំរបស់គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព ជាតំណាងអង្គការសង្គមស៊ីវិលដែលកំពុងអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានកម្មវិធីសុខភាពអង្គការ CRS ។
- ចំណាប់អារម្មណ៍របស់ **Mr. Joseph Scheuer, UN Resident Coordinator (អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ)** ប្រចាំនៅកម្ពុជា។
- អានសារលិខិត **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី- ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជាដោយលោកជំទាវ ម៉ែន នារីសោភ័គ អគ្គលេខាធិការរងទី១ កាកបាទក្រហមកម្ពុជា និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ។
- របាយការណ៍សង្ខេបស្តីពីការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាល និងស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាឆ្នាំ២០២៤ ដោយ ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉ែត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- អានសារលិខិត **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤ ដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**។
- ការអញ្ជើញនិវត្តន៍របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

៣. ដំណើរការនៃការប្រារព្ធទិវា

៣.១. ចំណាប់អារម្មណ៍របស់អ្នកស្រី ហាន សៀងហ៊ិន តំណាងអ្នកផ្តុកមេរោគអេដស៍

ជាកិច្ចចាប់ផ្តើម អ្នកស្រី ហាន សៀងហ៊ិន តំណាងអ្នកផ្តុកមេរោគអេដស៍ បានឡើងមានចំណាប់អារម្មណ៍ដែលមានខ្លឹមសារដូចខាងក្រោម៖

ថ្ងៃនេះអ្នកស្រីតំណាងឱ្យបងប្អូនដែលរស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគនៃក្រសួងសុខាភិបាល អង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ដែល

បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ថែទាំ ព្យាបាលសុខភាព និងផ្តល់ការគាំទ្រ ទាំងផ្នែកសម្ភារៈ ស្មារតី និងផ្នែកសង្គម ដល់បងប្អូនដែលរស់នៅជាមួយមរោគអេដស៍អស់រយៈពេលជាច្រើនឆ្នាំកន្លងមក។

ថ្វីត្បិតមានភាពជោគជ័យនិងចំណុចល្អទាំងអស់នោះ តែបញ្ហាប្រឈមរបស់អ្នករស់នៅជាមួយមេរោគអេដស៍នៅតែមាន ដូចការរើសអើងដែលបានជួបប្រទៈនៅក្នុងសហគមន៍របស់ពួកគេ មិនហ៊ានប្រាប់ទៅអ្នកដទៃ ខ្លាចបាត់បង់ប្រាក់ចំណូលក្នុងការផ្គត់ផ្គង់គ្រួសារ ពិបាករកការងារធ្វើ ស្ថាប័នឯកជនមួយចំនួននៅមានការតម្រូវឱ្យធ្វើតេស្តរកមេរោគអេដស៍ សេវាព្យាបាលជំងឺផ្សេងៗរបស់រដ្ឋ និងឯកជននៅមានការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍។ ការរើសអើងលើអ្នករស់នៅជាមួយមេរោគអេដស៍ បានធ្វើឱ្យអ្នកផ្ទុកមេរោគអេដស៍មួយចំនួនខ្លាចមិនចេញមកធ្វើតេស្តរកមេរោគអេដស៍ និងទទួលការព្យាបាលឡើយ។

ជាបទពិសោធន៍ បញ្ហាដែលជួបប្រទៈក្នុងសហគមន៍ មិនត្រឹមតែប៉ះពាល់ដល់បុគ្គលដែលផ្ទុកមេរោគអេដស៍ ប្តី ប្រពន្ធ ឬកូននិងគ្រួសាររបស់ពួកគាត់ប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់សង្គមទាំងមូលទៀតផង។ ជាក់ស្តែងពួកគាត់មិនហ៊ានប្រាប់គេ ខ្លាចគេមិនឱ្យការងារធ្វើ រាល់ពេលមកទទួលសេវាជំងឺអេដស៍តែងតែសុំច្បាប់ កុហក យកលេស ទៅពិនិត្យរោគស្ត្រី ឬក៏ថាមានការរវល់ក្នុងគ្រួសារជាដើម។ បញ្ហាប្រឈមខ្លាំងលើក្រុមប្រជាជនគន្លឹះ ដូចជាបុរសស្រឡាញ់បុរស អ្នកធ្វើការនៅតាមសៅកំសាន្ត អ្នកបំផ្លែងភេទ អ្នកចាក់គ្រឿងញៀន និងអ្នកប្រើប្រាស់ញៀនគ្រឿង ដែលមានអាយុចន្លោះពី ១៨ទៅ២៤ឆ្នាំ មានការព្រួយបារម្ភណ៍យ៉ាងខ្លាំងដែលពួកគាត់ជាយុវជន យុវតីទំពាំងស្នងឫស្សី។ បច្ចុប្បន្ននេះ សមាគមបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ហើយមានតែសហគមន៍ទេដែលដឹងច្បាស់ពីតម្រូវការរបស់អ្នកផ្ទុកមេរោគអេដស៍ និងក្រុមក្រុមប្រជាជនគន្លឹះ និងអាចជួយដោះស្រាយបញ្ហាបានទាន់ពេលវេលា។ ទន្ទឹមនឹងភាពជោគជ័យទាំងនេះ សហគមន៍អ្នកផ្ទុកមេរោគអេដស៍នៅតែត្រូវការសេវាបន្ត សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍អស់មួយជីវិត ព្រមទាំងសេវាថែទាំ និងគាំទ្រសង្គមផ្សេងៗមួយចំនួនទៀត ជាអាហារូបត្ថម្ភ ការទទួលបានការងារសមស្របទីជម្រក សេវាផ្នែកច្បាប់ និងទទួលបាននូវកិច្চគាំពារសង្គម បានទូលំទូលាយថែមទៀត ដើម្បីឱ្យជីវភាពរស់នៅមានភាពប្រសើរឡើង ដែលអាចនាំឱ្យពួកគាត់មិនធ្វើចំណាកស្រុក និងមិនបោះបង់ការលេបថ្នាំជាដើម។ អ្នកផ្ទុកមេរោគអេដស៍ចាំបាច់ត្រូវការថ្នាំប្រឆាំងមេរោគអេដស៍មួយជីវិតដែលមិនអាចអត់បាន។ ដើម្បីឱ្យមានការកាត់បន្ថយការចម្លងមេរោគអេដស៍ ស្នើសុំឱ្យគ្រប់ក្រសួង ស្ថាប័នបង្កើត និងពង្រឹងការផ្សព្វផ្សាយពីច្បាប់អេដស៍ ពីការបង្ការការឆ្លងមេរោគអេដស៍ ពិសេសក្រសួងព័ត៌មាន ក្រសួងអប់រំយុវជន និងកីឡា មេត្តាជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់យុវវ័យ និងសាធារណជន។ ដោយសារតែថវិកាជំនួយមានការកាត់បន្ថយ អ្នកផ្ទុកមេរោគអេដស៍មានក្តីព្រួយបារម្ភ ដែលសកម្មភាពមួយចំនួនអនុវត្តមិនបានពេញលេញ ឬបញ្ឈប់តែម្តង ជាពិសេសសកម្មភាពការជួបប្រជុំក្រុមអ្នកផ្ទុកមេរោគអេដស៍ ការផ្តល់ប្រឹក្សា និងគាំទ្រសម្របសម្រួលដោយអ្នកផ្ទុកមេរោគអេដស៍នៅកន្លែងផ្តល់សេវាឱសថប្រឆាំងមេរោគអេដស៍ និងការអនុវត្តន៍សកម្មភាពក្នុងសហគមន៍ ត្រូវបានកាត់បន្ថយច្រើន។

ស្នើសូមឱ្យបន្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ដែលដឹកនាំដោយសហគមន៍ស្របនឹងគោលដៅរបស់អង្គការUNAIDSគឺ៖

១-៨០%នៃសេវាបង្ការ ត្រូវតែផ្តល់ដោយសហគន៍ក្រុមប្រជាជនគន្លឹះ(បុរសរួមភេទជាមួយបុរស អ្នកធ្វើការនៅសេវាកម្សាន អ្នកបំផ្លែងភេទ អ្នកចាក់គ្រឿងញៀន និងអ្នកប្រើប្រាស់គ្រឿងញៀន TG និងក្រុមប្រឈមផ្សេងទៀត។

២. ៣០% នៃសេវាធ្វើតេស្ត និងព្យាបាលថែទាំមេរោគអេដស៍ ត្រូវតែអនុវត្តដោយអង្គការសហគមន៍។

៣. ៦០% នៃលើការផ្តល់បរិយាកាសអំណោយផល ការផ្សព្វផ្សាយ ការរើសអើង និងការគាំទ្រសូមរាជរដ្ឋាភិបាលកម្ពុជា ម្ចាស់ជំនួយបន្តការគាំទ្រថវិកាក្នុងការអនុវត្តន៍សកម្មភាពរបស់អ្នករស់នៅជាមួយមេរោគអេដស៍ ក្រុមងាយរងគ្រោះឱ្យពេញទំហឹង។ ដើម្បីដោះស្រាយការម៉ាក់ងាយ និងការរើសអើងក្នុងសហគមន៍ កន្លែងធ្វើការងារ កន្លែងផ្តល់សេវា របស់សុខាភិបាល និងការគោរពសិទ្ធិផ្សេងទៀតរបស់អ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ ដើម្បីឱ្យគាត់បានមកទទួលសេវាពេញលេញ ហើយរួមគ្នាដោះស្រាយឧបសគ្គក្នុងការទទួលបានសេវា ដើម្បីឈានឆ្ពោះទៅការបញ្ចប់ជំងឺអេដស៍។ សូមឱ្យរដ្ឋាភិបាលកម្ពុជា អង្គការដៃគូរពិចារណាពិភាក្សា និងជួយដោះស្រាយបញ្ហាទាំងអស់នោះ ដើម្បីធានាថា មានសេវាទាំងអស់។ ហេតុនេះ ស្នើសូមរាជរដ្ឋាភិបាល បន្តការជួយគាំទ្រសកម្មភាពក្នុងការជួយដល់ក្រុមដែលងាយរងគ្រោះ និងក្រុមអ្នកផ្ទុកមេរោគអេដស៍បន្តទៀត។

៣.២ ចំណាប់អារម្មណ៍របស់ លោកវេជ្ជបណ្ឌិត សុខ ប៊ុន តំណាងប្រធានគណៈកម្មាធិការដឹកនាំរបស់គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព៖

តាងនាមឱ្យអង្គការសង្គមស៊ីវិល ដែលបាននឹងកំពុងអនុវត្តកម្មវិធីលើកកម្ពស់សុខភាពជាពិសេស កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមជាកិត្តិយស និងថ្លែងមតិនៅក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤ នាថ្ងៃនេះ ដែលប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសនានានៅលើពិភពលោក បាននឹងកំពុងរៀបចំក្រោមប្រធានបទ **សិទ្ធិ ជាមាគ៌ាឆ្ពោះទៅបញ្ចប់អេដស៍** ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍នេះ គឺត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីការចូលរួម និងការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកដែលកំពុងរងផលប៉ះពាល់ដោយសារមេរោគអេដស៍និងជំងឺអេដស៍ ក៏ដូចជាដើម្បីបង្ហាញពីកិច្ចខិតខំប្រឹងប្រែងនៃការចូលរួមជាពហុវិស័យរបស់ស្ថាប័នពាក់ព័ន្ធក្នុងការទប់ស្កាត់ និងលុបបំបាត់ការរើករាលដាលនៃមេរោគអេដស៍ឱ្យសម្រេចបាននូវគោលដៅដែលបានគ្រោងទុកនៅឆ្នាំ២០៣០។

អង្គការសង្គមស៊ីវិលបានបន្តប្តេជ្ញានឹងចូលរួមឱ្យបានសកម្មថែមទៀត ដើម្បីឱ្យកម្ពុជាសម្រេចបាននូវគោលដៅ៩៥ទាំងបីនៅឆ្នាំ២០២៥ ជាពិសេសគោលដៅទី១ ដោយបន្តចូលរួមឱ្យកាន់តែសកម្មក្នុងការស្វែងរកអ្នកដែលសង្ស័យថាមានផ្ទុកមេរោគអេដស៍ ឱ្យឆាប់ទទួលបានការធ្វើ

តេស្តរកមេរោគអេដស៍ និងឆាប់ទទួលបានការព្យាបាល ប្រសិនជាគេមានផ្ទុកមេរោគអេដស៍។ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៤ ក្រោមប្រធានបទ **សិទ្ធិ ជាមាគ៌ាឆ្ពោះទៅបញ្ចប់អេដស៍** បានបញ្ជាក់ឱ្យឃើញនូវភាពចាំបាច់នៃសិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលមានផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ក្នុងការទទួលបានសេវាពេញលេញ ដោយមិនមានការមាក់ងាយ ការរើសអើង និងការផ្តល់សេវាប្រកបដោយមេត្រីភាព។ កន្លងមកនៅក្នុងសហគមន៍មានអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ បានជួបប្រទៈនឹងបញ្ហាជាច្រើនទាក់ទងនឹងសិទ្ធិ មានដូចជាការមាក់ងាយ និងការរើសអើងពីសមាជិកក្រុមគ្រួសារ សហគមន៍ និងអ្នកផ្តល់សេវាសុខាភិបាល ការលាតត្រដាងព័ត៌មានបុគ្គលដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិឯកជនភាពរបស់អ្នកផ្ទុកមេរោគអេដស៍ ការប៉ះពាល់ផ្លូវចិត្ត បូករួមទាំងនៅឯមួយចំនួនទាក់ទងនឹងច្បាប់ គោលនយោបាយ ការបង្ខំឱ្យស្នៀតពាក់ដែលបែងចែករវាងប្រុសនិងស្រី ការបង្ខំឱ្យកាត់សក់ ការបៀតបៀនកេរ្តិ៍ខ្មាស់ ការបង្ខំពីសំណាក់ក្រុមគ្រួសារឱ្យប្តូរអត្តសញ្ញាណដែលមិនចង់ ការដេរតិះដៀលពីសំណាក់មិត្តភ័ក្តិនិងបងប្អូន។ ជាងនេះទៅទៀត ការរើសអើង និងការខ្មាសអៀនដោយខ្លួនឯងក្នុងចំណោមសហគមន៍ក៏ជាឧបសគ្គមួយផងដែរ ក្នុងការចេញមកទទួលយកសេវាអប់រំ ការធ្វើតេស្តរកមេរោគអេដស៍ និងការមកទទួលយកការព្យាបាលមេរោគអេដស៍ និងជំងឺអេដស៍ផងដែរ។ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤ បានអំពាវនាវឱ្យមានការរួមគ្នារវាងអ្នករៀបចំគោលនយោបាយ អ្នកផ្តល់សេវា និងអ្នកទទួលសេវាទាំងអស់ឱ្យទទួលស្គាល់ និងឆ្លើយតបចំពោះវិសមភាព ក្នុងការទទួលបានសេវាចាំបាច់ដែលពាក់ព័ន្ធនឹងមេរោគអេដស៍ សម្រាប់ក្រុមប្រឈមមុខខ្ពស់នៃការឆ្លងមេរោគអេដស៍ ដែលរួមមានបុរសរួមភេទជាមួយបុរសក្រុមអ្នកបំប្លែងភេទ ក្រុមជនរងគ្រោះនៃការប្រើគ្រឿងញៀន ក្រុមស្ត្រីបម្រើការនៅតាមសេវាកម្សាន្ត និងដៃគូរបស់ពួកគេ។ ជាងនេះទៅទៀត ការចូលរួមរបស់សហគមន៍ក្នុងការដឹកនាំ និងការអនុវត្តសកម្មភាពនានា ជាធាតុចូលដ៏សំខាន់មួយក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ ក៏ដូចជាចូលរួមក្នុងការធ្វើឱ្យមាននិរន្តរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ផងដែរ។ ក្នុងគោលដៅកម្ពុជាឆ្ពោះទៅសម្រេចបានការលុបបំបាត់ការឆ្លងមេរោគថ្មីនាឆ្នាំ២០២៥នៃគោលដៅ៩៥% ៩៥% និង៩៥% អង្គការសង្គមស៊ីវិលផ្នែកសុខភាពមានជំនឿយ៉ាងមុតមាំថា កម្ពុជាពិតជាអាចធ្វើបាន ដោយបន្តនូវយុទ្ធសាស្ត្រឆ្លើយតបទៅនឹងជំងឺអេដស៍ជាលក្ខណៈពហុវិស័យ បន្តលុបបំបាត់គម្លាតរវាងអ្នកផ្តល់សេវានិងអ្នកទទួលសេវា លុបបំបាត់នូវការប្រមាថមាក់ងាយ ការរើសអើងទៅលើក្រុមអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខដទៃផ្សេងទៀតទាំងនៅកម្រិតគ្រួសារ សង្គម និងនៅកន្លែងផ្តល់សេវាពាក់ព័ន្ធ បង្កើតនិងពង្រឹងឱ្យមានសេវាមេត្រីកាន់តែមានច្រើននៅគ្រប់មូលដ្ឋានសុខាភិបាល និងផ្តល់ការគាំទ្រលើកទឹកចិត្តដល់អ្នករស់នៅជាមួយមេរោគអេដស៍និងក្រុមប្រឈមមុខឱ្យទទួលបានសេវាបង្ការ និងសេវាព្យាបាលជំងឺអេដស៍កាន់តែឆាប់ និងទាន់ពេលវេលា។

ដើម្បីឱ្យកម្ពុជាបន្តទទួលបានជោគជ័យលើគោលដៅដែលបានគ្រោងទុក និងដើម្បីឆ្លើយតបទៅនឹងប្រធានបទ **សិទ្ធិ ជាមាគ៌ាឆ្ពោះទៅបញ្ចប់អេដស៍** អង្គការសង្គមស៊ីវិល ស្នើសុំដូចខាងក្រោម៖

១. បង្កើនការយល់ដឹងពីក្រមសីលធម៌របស់អ្នកផ្តល់សេវា និងសិទ្ធិនៃអ្នកមកទទួលសេវា នៅតាមមូលដ្ឋានផ្តល់សេវាសុខាភិបាលទាំងអស់។

២. បង្កើនការយល់ដឹងនៅតាមសហគមន៍ឱ្យបានទូលំទូលាយ ស្តីពី SOGIESC (Sexual Orientation, Gender Identify and Expression, and Sex Characteristics)។

៣. បន្តសម្របសម្រួលក្នុងផ្តល់ប័ណ្ណសមធម៌ និងប័ណ្ណមូលនិធិសមធម៌សុខាភិបាលដល់អ្នកផ្ទុកមេរោគអេដស៍ និងក្រុមដែលងាយប្រឈមមុខខ្ពស់ដទៃផ្សេងទៀត។

៤. ស្នើសុំរាជរដ្ឋាភិបាលអនុវត្តយន្តការកិច្ចសន្យាសង្គម (Social Contracting) ដល់អង្គការសង្គមស៊ីវិលឱ្យមានធនធាន និងនៅតែបន្តបេសកកម្មរបស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងបញ្ហាមេរោគអេដស៍ប្រកបដោយប្រសិទ្ធិភាពនិងមាននិរន្តរភាព ជាពិសេសសម្រាប់ការងារអប់រំបង្ការ និងការពង្រឹងទៅលើភាពជាបណ្តាញនៃក្រុមប្រឈមមុខខ្ពស់។

៥. បន្តពង្រីកឱ្យមានការប្រើប្រាស់ថវិកាឃុំ សង្កាត់ ដើម្បីអនុវត្តកម្មវិធីអេដស៍នៅតាមសហគមន៍ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល។

៦. ជំរុញឱ្យមានតំណាងសហគមន៍ រួមមានអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ក្នុងសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់។

៧. សូមលើកទឹកចិត្តដល់បងប្អូនសហគមន៍ ត្រូវហ៊ានចេញមុខមកទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីសុំការគាំទ្រនិងការផ្តល់ប័ណ្ណមូលនិធិសមធម៌។

៨. សំណូមពរឱ្យមានការលើកទឹកចិត្តដល់បងប្អូនដែលមានការសង្ស័យថា មានផ្ទុកមេរោគអេដស៍ សូមឆាប់ទៅទទួលយកសេវាប្រឹក្សា និងធ្វើតេស្តឈាមដែលមាននៅតាមសហគមន៍ និងនៅតាមមន្ទីរពេទ្យបង្អែកទូទាំងប្រទេស ហើយឆាប់ទទួលយកការព្យាបាលឱ្យបានជាប់លាប់ ដើម្បីសុខភាពបុគ្គលខ្លួនឯងមនុស្សជាទីស្រឡាញ់ គ្រួសារនិងសហគមន៍។

ជាទីបញ្ចប់ ក្នុងនាមអង្គការសង្គមស៊ីវិល បានគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលតែងតែបានយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រក្នុងការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយជោគជ័យលើការងារនេះ ទាំងនៅក្នុងតំបន់ និងទាំងនៅលើសកលលោក។ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អាជ្ញាធរមូលដ្ឋាននៅគ្រប់ជាន់ថ្នាក់ ព្រមទាំងក្រសួងមន្ទីរពាក់ព័ន្ធសម្រាប់ការជួយជ្រោមជ្រែង និងការសហការដ៏រលូន ដែលធ្វើឱ្យសហគមន៍ និងអង្គការសង្គមស៊ីវិល ដំណើរការកម្មវិធីរបស់ខ្លួនប្រកបដោយជោគជ័យ។

ក្នុងឱកាសនេះ អង្គការសង្គមស៊ីវិលក៏បានថ្លែងអំណរគុណដល់អង្គការម្ចាស់ជំនួយ រួមមាន USAID GFATM មូលនិធិប្រទេសបារាំង (L' Initiative/Expertise France) និងដៃគូអភិវឌ្ឍន៍ផ្សេង

ទៀតសម្រាប់ការជួយគាំទ្រ ជួយសង្គ្រោះជីវិតអ្នករស់នៅជាមួយមេរោគអេដស៍រាប់រយពាន់នាក់ បានបន្តរស់រាន និងកសាងជីវភាពរស់នៅជាប្រក្រតីឡើងវិញនៅក្នុងសហគមន៍។

៣.៣.ចំណាប់អារម្មណ៍របស់ Mr. Joseph Scheuer, UN Resident Coordinator (អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ) ប្រចាំនៅកម្ពុជា

ជាកិច្ចចាប់ផ្តើមលោក Joseph Scheuer អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានឡើងចំណាប់អារម្មណ៍ ដែលមានខ្លឹមសារដូចខាងក្រោម៖

តំណាងឱ្យក្រុមការងារសហប្រជាជាតិរួមគ្នាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា បានលើកឡើងថា ជារៀងរាល់ឆ្នាំ នៅក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ យើងទាំងអស់គ្នាជួបជុំគ្នាដើម្បីចងចាំដល់មិត្តភក្តិ និងសមាជិកក្រុមគ្រួសារដែលបានស្លាប់ដោយសារជំងឺអេដស៍ និងបង្ហាញពីសាមគ្គីភាពជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ និងអ្នកដែលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ទាំងអស់។

ប្រទេសកម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពយ៉ាងច្រើន នៅក្នុងការប្រយុទ្ធនឹងការរីករាលដាលមេរោគអេដស៍ ហើយបានក្លាយជាប្រទេសគំរូមួយសម្រាប់ប្រទេសផ្សេងៗទៀតនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងក្នុងសកលលោក។ កស្តុតាងនៃវឌ្ឍនភាពទាំងនេះ រួមមានការធ្លាក់ចុះ៤៥% ចំនួនករណីឆ្លងថ្មីនៃមេរោគអេដស៍ និងការធ្លាក់ចុះ៣៦%នៃការស្លាប់ដែលពាក់ព័ន្ធនឹងជំងឺអេដស៍ នៅចន្លោះរវាងឆ្នាំ២០១០ និង ២០២៣។ លើសពីនេះទៀត ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានអត្រាគ្របដណ្តប់ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ខ្ពស់ជាងគេក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលក្នុងនោះ ៨៩%នៃចំនួនប៉ាន់ស្មានអ្នករស់នៅជាមួយមេរោគអេដស៍សរុប៧៦.០០០នាក់ នៅទូទាំងប្រទេស កំពុងទទួលបានការព្យាបាលសង្គ្រោះជីវិតនៅត្រឹមចុងឆ្នាំ២០២៣ ហើយ៨៧%មានបន្ទុកមេរោគ ត្រូវបានបង្ក្រាបមកនៅកម្រិតទាបបំផុត។ សមិទ្ធិផលនៅកម្ពុជា គឺជាសក្ខីភាពនៃការប្តេជ្ញាចិត្តខ្ពស់ផ្នែកនយោបាយ និងភាពជាដៃគូដែលផ្តល់នូវវិធីសាស្ត្រផ្អែកលើកស្តុតាង និងផ្អែកលើសិទ្ធិ ដែលដាក់អ្នករស់នៅជាមួយមេរោគអេដស៍ និងប្រជាជនគន្លឹះ ជាស្នូលនៃការឆ្លើយតបនឹងមេរោគអេដស៍។

ភាពជាអ្នកដឹកនាំ ដែលរដ្ឋាភិបាលកម្ពុជាបានបង្ហាញក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងភាពជាដៃគូយ៉ាងជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ សង្គមស៊ីវិល អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត គឺជាមូលដ្ឋានគ្រឹះចំពោះការរីកចម្រើន និងសមិទ្ធិផលជាបន្តបន្ទាប់របស់ប្រទេសក្នុងការឆ្លើយតបនឹងមេរោគអេដស៍។ ភាពជាអ្នកដឹកនាំដ៏មុតមាំនេះ អាចបង្កើតសង្គមស្មើភាព និងជានាសិទ្ធិចំពោះសុខភាពសម្រាប់ទាំងអស់គ្នា ដោយដោះស្រាយបញ្ហាវិសមភាព។ ប៉ុន្តែយើងមិនគួរភ្លេចខ្លួននោះទេ ការរីករាលដាលមេរោគអេដស៍មិនទាន់ចប់នៅឡើយ ហើយការឆ្លើយតបនឹងមេរោគអេដស៍ប្រកបដោយនិរន្តរភាពនៅកម្ពុជា នៅមិនទាន់ច្បាស់លាស់នៅឡើយដែរ ហើយកម្ពុជាបានប្តេជ្ញាចិត្តបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ តែយើងមិនទាន់ស្ថិតនៅលើផ្លូវដើម្បីសម្រេចបានគោលដៅនេះទេ។ ទោះបីជាមានការគ្របដណ្តប់ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ខ្ពស់ក៏ដោយ មានតែ៥៦%នៃកុមាររស់នៅជាមួយមេរោគអេដស៍តែប៉ុណ្ណោះ ដែលកំពុងទទួលបានការ

ព្យាបាល។ មេរោគអេដស៍នៅបន្តជះឥទ្ធិពលដល់ក្រុមប្រជាជនគន្លឹះ រួមមានស្ត្រីធ្វើការតាមគ្រឹះស្ថានកម្សាន្ត បុរសរួមភេទជាមួយបុរស អ្នកចាក់គ្រឿងញៀន និងស្ត្រីបំផ្លែងភេទ។ ក្នុងឆ្នាំ២០២៣កន្លងទៅ ៨៦%នៃករណីឆ្លងថ្មីនៃមេរោគអេដស៍ គឺស្ថិតក្នុងចំណោមក្រុមប្រជាជនគន្លឹះ និងដៃគូរួមភេទរបស់ពួកគេ ហើយយើងមើលឃើញភាពងាយរងគ្រោះចំពោះការឆ្លងមេរោគអេដស៍ មានការកើនឡើងក្នុងចំណោមប្រជាជនគន្លឹះវ័យក្មេង ជាពិសេសបុរសវ័យក្មេងដែលរួមភេទជាមួយបុរស និងស្ត្រីបំផ្លែងភេទវ័យក្មេង។ លើសពីនេះទៅទៀត អ្នករស់នៅជាមួយមេរោគអេដស៍ និងប្រជាជនគន្លឹះនៅតែបន្តប្រឈមនឹងឧបសគ្គក្នុងការទទួលបានសេវាទាក់ទងនឹងមេរោគអេដស៍ ដោយសារការមាក់ងាយ និងការរើសអើងឧបសគ្គផ្នែកច្បាប់ និងគោលនយោបាយមួយចំនួន ដូចជាការដាក់ទោសទណ្ឌលើទិដ្ឋភាពមួយចំនួននៃការងារផ្តល់សេវាផ្លូវភេទ និងការប្រើប្រាស់គ្រឿងញៀន ក៏ដូចជាច្បាប់ដែលកំណត់អាយុនៃការផ្តល់ការព្រមព្រៀងក្នុងការទទួលសេវាថែទាំ ព្យាបាលមេរោគអេដស៍ដែលអាចរារាំងមនុស្សវ័យក្មេងពីការទទួលបានសេវាថែទាំ ព្យាបាលមេរោគអេដស៍ដោយសេរី ក្រោមការព្រមព្រៀងរបស់ខ្លួនផ្ទាល់។ ក្នុងនាមជាអ្នកមានកាតព្វកិច្ចសម្រាប់សិទ្ធិមនុស្ស រដ្ឋាភិបាលកម្ពុជាអាចបំពេញការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីការពារសិទ្ធិជាមូលដ្ឋាន និងសេរីភាពក្នុងបរិបទនៃមេរោគអេដស៍ ការធ្វើដូច្នេះនឹងអាចបញ្ចៀសការរងទុក្ខរបស់មនុស្ស លើកកម្ពស់ការអភិវឌ្ឍដ៏ល្អ និងសន្សំធនធានហិរញ្ញវត្ថុក្នុងរយៈពេលវែង។

របាយការណ៍សកលថ្មីរបស់អង្គការUNAIDSបានបង្ហាញថា ពិភពលោកអាចសម្រេចបានគោលដៅដែលបានព្រមព្រៀងគ្នាក្នុងការបញ្ចប់ជំងឺអេដស៍ ជាការគំរាមកំហែងសុខភាពសាធារណៈនៅឆ្នាំ២០៣០ ប៉ុន្តែជារាបណាមេដឹកនាំការពារសិទ្ធិមនុស្សរបស់មនុស្សគ្រប់រូបដែលរស់នៅ និងប្រឈមនឹងការឆ្លងមេរោគអេដស៍។ ការលើកកម្ពស់សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ពីសិទ្ធិមនុស្ស និងការជំរុញការរួមបញ្ចូលសហគមន៍ទាំងអស់ គឺចាំបាច់សម្រាប់ការបញ្ចប់ជំងឺអេដស៍ ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងសម្រាប់សន្តិសុខមនុស្សជាតិ។

ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូនេះផងដែរ ក៏បានអំពាវនាវដល់រដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលទាំងអស់៖

- តស៊ូមតិសម្រាប់ការការពារសិទ្ធិមនុស្ស និងការលុបបំបាត់ឧបសគ្គផ្នែកច្បាប់ ដែលរារាំងការទទួលបានសេវាថែទាំ ព្យាបាលមេរោគអេដស៍ រួមមានក្របខណ្ឌច្បាប់ និងគោលនយោបាយដើម្បីលុបបំបាត់ការមាក់ងាយ និងការរើសអើង បញ្ឈប់ការដាក់ទោសទណ្ឌលើទិដ្ឋភាពមួយចំនួននៃការងារផ្តល់សេវាផ្លូវភេទ និងការប្រើប្រាស់គ្រឿងញៀន ដែលរារាំងការទទួលបានសេវាថែទាំ ព្យាបាលមេរោគអេដស៍របស់ប្រជាជនគន្លឹះ ដើម្បីជានាការព្រមព្រៀងសមស្របតាមអាយុដែលអនុញ្ញាតឱ្យយុវវ័យទទួលបានសេវាថែទាំ ព្យាបាលមេរោគអេដស៍ដោយសេរី និងរក្សាការសម្ងាត់។
- បញ្ជាបការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្ស និងប្រើប្រាស់ទិដ្ឋភាពសមធម៌នៅក្នុងការឆ្លើយតបនឹងមេរោគអេដស៍ រួមទាំងប្រែក្លាយការប្តេជ្ញាចិត្ត ស្តីពីសមភាពយេនឌ័រ និងមេរោគអេដស៍ទៅជាការពិត។
- សហការជាមួយសហគមន៍ដើម្បីរៀបចំ និងអនុវត្តសេវាថែទាំ ព្យាបាលមេរោគអេដស៍ដែលយកមនុស្សជាស្នូល អាចប្រើប្រាស់បាន មាននិរន្តរភាព និងអាចទទួលយកបានសម្រាប់ប្រជាជនគន្លឹះ រួមបញ្ចូលទាំងការធានាការឆ្លើយតបដែលដឹកនាំដោយសហគមន៍ និងអ្នកការពារសិទ្ធិមនុស្ស មានលំហគ្រប់គ្រាន់ ដើម្បីដឹកនាំកិច្ចខិតខំប្រឹងប្រែងដោយផ្តោតលើសិទ្ធិមនុស្សក្នុងការឆ្លើយតបនឹងមេរោគអេដស៍។
- វិនិយោគលើវិធីសាស្ត្រប្រកបដោយនិរន្តរភាព ច្នៃប្រឌិត និងមានលក្ខណៈខុសប្លែកគ្នា ក្នុងការផ្តល់សេវា ដើម្បីបំពេញតម្រូវការចម្រុះរបស់ប្រជាជនគន្លឹះ រួមទាំងការ

រក្សាឱ្យមាននិរន្តរភាព និងពង្រីកគំនិតផ្តួចផ្តើមដែលដឹកនាំដោយសហគមន៍ បានបង្ហាញថា មានប្រសិទ្ធភាពក្នុងការផ្តល់សេវាដល់អ្នកដែលត្រូវការបំផុត។

៣.៤ អានសារលិខិត សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា ដោយលោកជំទាវ ម៉ែន នារីសោភ័គ អគ្គលេខាធិការរងទី១កាកបាទក្រហមកម្ពុជា និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ។

ក្នុងនាមកាកបាទក្រហមកម្ពុជា ដែលមាន **សម្តេចព្រះមហាក្សត្រីនរោត្តមមុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាព្រះប្រធានកិត្តិយស និងក្នុងនាមសម្តេចកិត្តិព្រឹទ្ធបណ្ឌិតផ្ទាល់ ជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា សម្តេចកិត្តិព្រឹទ្ធបណ្ឌិតមានកិត្តិយស សូមចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ថ្នាក់ជាតិលើកទី៣១ និងថ្នាក់អន្តរជាតិលើកទី៣៦ ក្រោមប្រធានបទ **"សិទ្ធិ ជាមាគ៌ាឆ្ពោះទៅបញ្ចប់អេដស៍"** ។

ការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ជាឱកាសដ៏មានសារៈសំខាន់សម្រាប់គូសបញ្ជាក់ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ភាពមិនរើសអើងជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ និងការលើកកម្ពស់សិទ្ធិស្មើនៅស្មើមុខស្មើមាត់ជាមួយប្រជាពលរដ្ឋទូទៅក្នុងសង្គមជាតិ និងជាការបង្ហាញពីវឌ្ឍនភាពការងាររបស់រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** សម្រេចបានមួយឆ្នាំកន្លងមក ក្នុងការឈានឆ្ពោះទៅបញ្ចប់បញ្ហាអេដស៍នៅកម្ពុជា ដែលជារួមមាន៖

១. ផ្តល់ការបង្ការ ព្យាបាល ថែទាំ និងគាំទ្រទូលំទូលាយ និងមានប្រសិទ្ធភាព តាមរយៈការសម្របសម្រួលល្អ និងប្រើប្រាស់វិធីសាស្ត្រជំរុញការចូលរួមជាពហុវិស័យ រួមមាន អន្តរាគមន៍គន្លឹះនៃការបង្ការ ការធ្វើតេស្ត និងអត្រាវិជ្ជមានមេរោគអេដស៍ក្នុងចំណោមក្រុមប្រឈមទៅតាមក្រុម និងតាមត្រីមាស និងអន្តរាគមន៍គន្លឹះនៃការថែទាំ និងព្យាបាលជំងឺអេដស៍ ដើម្បីធនធានមនុស្សប្រកបដោយសុខភាពល្អ។

២. ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម និងបង្កើតបរិយាកាសអំណោយផល ឱ្យក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍បានទទួលសេវាអេដស៍ សេវាសុខាភិបាល និងសេវាគាំទ្រផ្នែកច្បាប់ និងសង្គមប្រកបដោយប្រសិទ្ធភាព តាមរយៈពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម លើកកម្ពស់ការបញ្ចប់ការមាក់ងាយ និងការរើសអើង ដោយប្រកាន់ខ្ជាប់គោលការណ៍សមភាព និងបរិយាបន្ន។

៣. កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបសហគមន៍ និងកែលម្អ ការធ្វើសមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និងវិស័យមិនមែនសុខាភិបាល។

៤. ជានាចីរភាពសមិទ្ធផលជាតិនៃការឆ្លើយតបនឹងមេរោគអេដស៍ ដោយការបង្កើតការវិនិយោគជាតិ និងការពង្រឹងប្រព័ន្ធប្រទេសឆ្លើយតបនឹងមេរោគអេដស៍ តាមរយៈអភិបាលកិច្ច សម្របសម្រួល និងត្រួតពិនិត្យ។

៥. ការជាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨។

ក្នុងនាមជាជំនួយការជូនអាជ្ញាធរសោធារណៈក្នុងវិស័យមនុស្សធម៌ កាកបាទក្រហមកម្ពុជា និងក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ នឹងបន្តពង្រឹងការចូលរួមជាមួយរាជរដ្ឋាភិបាលឱ្យបានទ្វេដង ដោយផ្តោតការយកចិត្តទុកដាក់ទៅលើអាទិភាពបីជាចម្បងគឺ៖ ទីមួយ៖ ការអប់រំលើកកម្ពស់ការយល់ដឹងពីការបង្ការការចម្លងមេរោគអេដស៍នៅក្នុងសហគមន៍ និងនៅតាមគ្រឹះស្ថានអប់រំ ជាពិសេសក្នុងចំណោមយុវវ័យ និងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ទីពីរ៖ ផ្តល់សេវាគាំទ្រសង្គមជួយជនរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍។ ទីបី៖ លើកកម្ពស់ការកាត់បន្ថយដើម្បីឈានទៅលុបបំបាត់ទាំងស្រុងរាល់ទម្រង់រើសអើង និងមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។

ឆ្លៀតក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៤ ដ៏មហោឡារិកនេះ លោកជំទាវបានផ្ញើសារមួយចំនួនជូនបងប្អូនជនរួមជាតិទាំងអស់ដូចខាងក្រោម៖

១. សូមចូលរួមយ៉ាងសកម្ម និងឱ្យបានទ្វេដងជាមួយរាជរដ្ឋាភិបាលកម្ពុជា និងកាកបាទក្រហមកម្ពុជាក្នុងយន្តការជាតិតែមួយ ដើម្បីពង្រឹងភាពជាអ្នកដឹកនាំសហគមន៍ឆ្លើយតបឱ្យបានទូលំទូលាយ និងពហុវិស័យគ្របដណ្តប់ទៅគ្រប់ភូមិសាស្ត្រ និងគ្រប់ក្រុមគោលដៅ។

២. ក្មួយៗជាយុវជន យុវនារី ត្រូវប្រកាន់យកនូវផ្នត់គំនិត និងឥរិយាបថវិជ្ជមាន ដោយប្រកាន់ខ្ជាប់នូវការអភិវឌ្ឍស្វែងយល់ជាប្រចាំ នូវចំណេះដឹងថ្មីៗស្តីពីការបង្ការការចម្លងមេរោគអេដស៍ ដើម្បីបង្ការខ្លួនយើង គ្រួសារយើង សហគមន៍យើង និងសង្គមជាតិយើង ពីការរាលដាលនៃមេរោគអេដស៍ ព្រោះថា "យើងអាចភ្លេចអេដស៍ តែអេដស៍ពុំភ្លេចយើងឡើយ"។

៣. អ្នកដែលបានប្រព្រឹត្ត ឬសង្ស័យថាខ្លួនបានប្រឈមនឹងការឆ្លងមេរោគអេដស៍ ចូរប្រញាប់រួសរាន់ ទៅស្វែងរកសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ដើម្បីឆាប់បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ដែលអាចប្រើប្រាស់ក្នុងការសម្រេចចិត្ត ទៅទទួលសេវាថែទាំ និងព្យាបាលបន្តបានទាន់ពេលវេលា។

៤. ស្ត្រីមានផ្ទៃពោះទាំងអស់ ចូរប្រញាប់រួសរាន់ស្វែងរកសេវាពិនិត្យ និងថែទាំផ្ទៃពោះឱ្យបានត្រឹមត្រូវ និងទៀងទាត់ទៅតាមការណែនាំរបស់បុគ្គលិកពេទ្យ ដើម្បីសុខភាពមាតា ទារក និងដើម្បីចូលរួមទប់ស្កាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅទារក។

៥. ត្រូវបញ្ឈប់ជាដាច់ខាតនូវគ្រប់ទម្រង់រើសអើង ឬមាក់ងាយទៅលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ព្រោះវាជាអំពើផ្ទុយទៅនឹងច្បាប់ស្តីពីការបង្ការ និងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

៦. ចំពោះអ្នកដែលមានមុខរបរ ឬមានការប្រព្រឹត្តប្រឈមខ្ពស់នឹងការឆ្លងមេរោគអេដស៍ ចូរប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% នៅរៀងរាល់ពេលដែលមានទំនាក់ទំនងរួមភេទ។

តាមរយៈសារខាងលើនេះ លោកជំទាវមានសង្ឃឹមយ៉ាងមុតមាំថា បងប្អូនជនរួមជាតិទាំងអស់ ពិតជាអាចប្រើប្រាស់បានក្នុងការធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ចូលរួមបញ្ចប់ជំងឺអេដស៍នៅកម្ពុជា និងជួយបន្តចែកចាយសារទាំងអស់នេះទៅកាន់សមាជិកក្រុមគ្រួសារ បងប្អូនមិត្តភក្តិ សហសេវិក។ល។

ជាមួយគ្នានេះ លោកជំទាវបានសូមអំពាវនាវឱ្យវិស័យឯកជនទាំងអស់បន្តភាពជាដៃគូជាមួយកាកបាទក្រហមកម្ពុជា ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលសម្រេចឱ្យបានគោលដៅបញ្ចប់ជំងឺអេដស៍នាឆ្នាំ២០២៥។

ជាទីបញ្ចប់នេះ លោកជំទាវបានជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ក្មួយៗ យុវជន និងបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបតែនឹងព្រះពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

៣.៥. របាយការណ៍សង្ខេបស្តីពីការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាល និងស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាឆ្នាំ២០២៤ ដោយឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉ែត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

ជាបឋម ឯកឧត្តមបណ្ឌិតអគ្គលេខាធិការ បានសម្តែងនូវគារវកិច្ចដ៏ឧត្តុង្គឧត្តមចំពោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ងួលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍នាឱកាសដ៏ថ្លៃថ្លានេះ។

ជារៀងរាល់ឆ្នាំ ដូចបណ្តាប្រទេសនានាក្នុងពិភពលោក ក្នុងនាមរាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តែងប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី១ធ្នូ ជាទៀងទាត់។ ការប្រារព្ធទិវានេះធ្វើឡើងក្នុងគោលបំណង បង្ហាញការប្តេជ្ញាចិត្តដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធនឹងការរីករាលដាលមេរោគអេដស៍ឈានទៅបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍នៅកម្ពុជា។ ទិវាក៏បានរំលឹកពីការផ្តល់នូវការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ រំលឹកដល់ការបាត់បង់ និងការស្លាប់ដោយសារជំងឺអេដស៍ ព្រមទាំងក្រើនរម្លឹកដល់ប្រជាពលរដ្ឋទូទាំងប្រទេស ឱ្យចងចាំពីគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ដើម្បីទាំងអស់គ្នាឈានទៅបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍ រួមចំណែកក្នុងការអភិវឌ្ឍមនុស្សជាតិដោយភាពសុខដុម។ ទន្ទឹមនឹងនេះ យើងលើកកម្ពស់ការយល់ដឹងអំពីជំងឺអេដស៍ ដោយបង្ហាញពីសារៈសំខាន់នៃចំណេះដឹងស្តីពីវិធានការបង្ការ និងគ្រប់គ្រងជំងឺអេដស៍។ មកដល់ពេលនេះ អេដស៍នៅតែជាជំងឺមួយគំរាមកំហែងដល់សុខភាពសាធារណៈរបស់មនុស្សជាតិនៅឡើយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតពីសំណាក់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងអស់ទាំងក្នុងតំបន់ និងទូទាំងពិភពលោក។

ក្រោមប្រធានបទ "**សិទ្ធិ ជាអាគ្រាន់ឆ្ពោះទៅបញ្ចប់អេដស៍**" យើងផ្តោតការយកចិត្តទុកដាក់ជាសំខាន់សិទ្ធិនៃអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ រួមទាំងសិទ្ធិនៃការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមក្នុងបទអន្តរាគមន៍នៅគ្រប់លំដាប់ថ្នាក់ ដែលជាមាគ៌ាឆ្ពោះទៅការបញ្ចប់អេដស៍នៅទូទាំងសកលលោក និងនៅកម្ពុជា។ ក្នុងឆន្ទៈមោះមុតឈានទៅបញ្ចប់អេដស៍ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ ហើយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានរៀបចំនូវផែនការយុទ្ធសាស្ត្រជាតិគោលការណ៍ណែនាំ ដោយមានការដាក់បញ្ចូលគ្រប់តួអង្គទៅក្នុងយន្តការឆ្លើយតបមេរោគអេដស៍ នៅគ្រប់លំដាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការពង្រឹងសមត្ថភាពសហគមន៍ និងការផ្តល់ឱកាសជូនតំណាងអ្នកផ្ទុកមេរោគអេដស៍ និងតំណាងប្រជាជនគន្លឹះនៅគ្រប់វេទិការជាតិ និងអន្តរជាតិ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាល អង្គការUNAIDS និងភ្នាក់ងារអភិវឌ្ឍអន្តរជាតិនានា។ គម្រោងតាមដានការឆ្លើយតបអេដស៍ដឹកនាំដោយសហគមន៍ ត្រូវបានពង្រឹងពីមួយថ្ងៃទៅមួយថ្ងៃ និងបានទទួលលទ្ធផលជាបន្តបន្ទាប់។

នាឱកាសដ៏វិសេសវិសាលនេះ ឯកឧត្តមបណ្ឌិត បានជម្រាបជូនអង្គពិធីទាំងមូល នូវស្ថានភាពនៃការរីករាលដាល និងសមិទ្ធផលនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្នាំ២០២៤ ចម្បងៗដូចតទៅ៖

- តាមរយៈការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល អ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ បង្កឱ្យអត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍បានថយចុះជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ មកនៅត្រឹមតែ០,៥% ក្នុងចំណោមមនុស្សពេញវ័យអាយុពី១៥ដល់៤៩ឆ្នាំ នៅឆ្នាំ២០២៣។
- អ្នកឆ្លងថ្មីក្នុងចំណោមមនុស្សពេញវ័យអាយុ១៥ឆ្នាំឡើង មានការថយចុះគួរឱ្យកត់សម្គាល់ប្រមាណជា ៤៦% បើគិតពីឆ្នាំ២០១០ មកដល់ឆ្នាំ២០២៣ ដែលក្នុងនោះមានការថយចុះក្នុងចំណោមស្ត្រីរហូតដល់៧៦% ក៏ប៉ុន្តែបែរជាមានការកើនឡើងក្នុងបុរសប្រមាណ៦%ទៅវិញ។នៅឆ្នាំ២០២៣អ្នកឆ្លងថ្មីមានចំនួន ១.២០០នាក់ ដែលតាមការវិភាគក៏បានបង្ហាញថា ៨៦% ចំណោមអ្នកឆ្លងថ្មី គឺជាប្រជាជនគន្លឹះ និងអតិថិជនរួមនឹងដៃគូ ដែលក្នុងនោះមាន ៤៦% ចំណោមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកបំប្លែងភេទ ១១% និងចំណែកអ្នកស្លាប់ដោយសារមេរោគអេដស៍មានចំនួន១.១០០នាក់ (មានការថយចំនួន១០០នាក់ បើប្រៀបធៀបនឹងតួលេខក្នុងឆ្នាំ២០២១ ដែលមានចំនួន១.៣០០នាក់)។
- តាមការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រ នៅក្នុងឆ្នាំ២០២៣បានបង្ហាញថា ចំនួនប៉ាន់ស្មានអ្នកផ្ទុកមេរោគអេដស៍សរុបមានប្រមាណ ៧៦.០០០នាក់។ ក្នុងនោះនៅត្រីមាសទី៣ឆ្នាំ២០២៤នេះ អ្នកមកទទួលសេវាព្យាបាលថែទាំដោយឱសថប្រឆាំងមេរោគអេដស៍មានចំនួន៦៩.៤៣១នាក់។ បើធៀបនឹងគោលដៅជាតិ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៣ កម្ពុជាសម្រេចបាន ៨៩-៩៨-៩៨ នៃគោលដៅ មានន័យថា៖
    - ✓ ៨៩%នៃអ្នកផ្ទុកមេរោគអេដស៍ បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន។

- ✓ ៩៨%នៃអ្នកផ្ទុកមេរោគអេដស៍ដែលដឹងពីស្ថានភាព បានទទួលការព្យាបាល។
- ✓ ៩៨%នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានទទួលការព្យាបាល ត្រូវបានពិនិត្យឃើញមានបន្ទុកមេរោគអេដស៍កម្រិតទាប។

- តាមរយៈលទ្ធផលខាងលើនេះ ក្នុងការបិទបញ្ចប់អេដស៍ នៅសល់តែគោលដៅទី១ប៉ុណ្ណោះ ដែលមិនទាន់បានសម្រេច។
- យើងបានពង្រីកសេវាលេបថ្នាំបង្ការការឆ្លងមេរោគអេដស៍មុនការប្រព្រឹត្តិប្រឈម (PrEP) បានយ៉ាងឆាប់រហ័សរហួតដល់៤៣កន្លែង ដែលមានក្រុមប្រជាជនគន្លឹះមកទទួលសេវារហួតដល់២៧.១៦៩នាក់ (គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២៤)។
- ក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ការគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ មានអ្នកផ្ទុកមេរោគអេដស៍ចំនួន៤៦.២០២នាក់ (ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ ដែលកំពុងទទួលការព្យាបាល៦៩.៤១៣នាក់)ស្មើនឹង ៦៧% បានទទួលបំណ្ណសមធម៌ពីរដ្ឋាភិបាល។
- ក្នុងកិច្ចខិតខំប្រឹងប្រែងការបញ្ចប់ការមាក់ងាយ និងការរើសអើង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការយូអិនអេដស៍ អង្គការសង្គមស៊ីវិល តំណាងសហគមន៍ បាន និងកំពុងអនុវត្តផែនការសកម្មភាពជាតិសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ ទាក់ទងនឹងការមាក់ងាយនិងការរើសអើង ដោយផ្តោតលើវិស័យសុខាភិបាល វិស័យអប់រំ និងសហគមន៍ និងបានជំរុញអនុវត្តគោលការណ៍ណែនាំសម្រាប់យន្តការរាយការណ៍ និងការឆ្លើយតបចំពោះការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ ដើម្បីកាត់បន្ថយ និងឈានលុបបំបាត់បាននូវការមាក់ងាយ និងរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។

ទោះបីកម្ពុជាយើងបានទទួលនូវលទ្ធផលល្អគួរជាទីមោទនៈជាបន្តបន្ទាប់ក្តី ក៏បញ្ហាអេដស៍នៅមិនទាន់បញ្ចប់នៅឡើយ។ នៅឆ្នាំ២០២៣ក្នុងចំណោមករណីឆ្លងថ្មីនៃមេរោគអេដស៍១.២០០នាក់ គឺយុវវ័យអាយុពី១៥-២៤ឆ្នាំ ចំនួន៥១៦នាក់ ត្រូវជាប្រមាណ៤៣%។ ការយល់ដឹងទូលំទូលាយ និងត្រឹមត្រូវអំពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមយុវវ័យមានកម្រិតទាប ប្រមាណតែ២៣% ធ្លាក់ចុះគួរកត់សម្គាល់ពី៣៨%នៅឆ្នាំ២០១៤ និង៤៤%នៅឆ្នាំ២០១០ រួមផ្សំនឹងការប្រើប្រាស់ស្រោមអនាម័យមានកម្រិតទាប ការរួមភេទជាក្រុម ដែលជាហេតុធ្វើឱ្យអត្រាប្រាំឡង់ជំងឺកាមរោគ និងប្រាំឡង់មេរោគអេដស៍មានកម្រិតខ្ពស់គួរឱ្យព្រួយបារម្ភ។ លើសពីនេះទៅទៀត អត្រាចម្លងមេរោគពីម្តាយទៅកូននៅមានកម្រិតខ្ពស់ ប្រមាណ៨% ដែលទាមទារធ្វើឱ្យសម្រេចទៅតាមគោលដៅកំណត់គឺតិចជាង៥%។

បញ្ហាទាំងឡាយខាងលើ កំពុងជាឧបសគ្គរារាំងដល់វឌ្ឍនភាពក្នុងការឈានទៅបិទបញ្ចប់ជំងឺអេដស៍។ យើងទាំងអស់គ្នា ត្រូវធ្វើសកម្មភាពជាក់ស្តែងចាំបាច់បន្ថែម ដោយបង្កើនបទអន្តរាគន៍បង្ការប្រកបដោយគុណភាព និងជំរុញការស្វែងរកករណីថ្មីនៃមេរោគអេដស៍ ដោយបង្កើនការគាំទ្រ និងជំរុញការចូលរួមពីសហគមន៍ បង្កើនការគោរពសិទ្ធិ ដែលជាមាគ៌ាឆ្ពោះទៅការបញ្ចប់អេដស៍ តាមការប្តេជ្ញាចិត្តរបស់យើង។ លើសពីនេះទៅទៀត កំណែទម្រង់ច្បាប់ គោលនយោបាយ បទអន្តរាគមន៍ និង

ការអនុវត្តវិធាននានាក៏ត្រូវតែមានការយកចិត្តទុកដាក់បន្ថែមទៀត។ តាមរយៈការសិក្សាវាយតម្លៃថ្នាក់ជាតិ ស្តីពីការចំណាយការឆ្លើយតបអេដស៍នៅកម្ពុជា បានបង្ហាញថាហិរញ្ញប្បទានពីខាងក្រៅមានការថយចុះជាបណ្តើរៗ ទន្ទឹមនឹងការកើនឡើងហិរញ្ញប្បទានក្នុងស្រុក ក៏ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់ទៅតាមសេណារីយ៉ូនៃការវិនិយោគដែលមានប្រសិទ្ធភាពខ្ពស់នៅឡើយ។

សមាសធាតុគន្លឹះបី ដែលជាសរសៃស្នូលទ្រទ្រង់ការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ប្រកបប្រសិទ្ធភាព ចីរភាព និងភាពធន់ ដែលកម្ពុជាបាន និងកំពុងអនុវត្ត រួមមានៈ ១)មគ្គុទ្ទេសភាព និងភាពជាម្ចាស់ ២) ភាពជាដៃគូ និង ៣) ការវិនិយោគ។ ក្នុងមគ្គុទ្ទេសភាព និងភាពជាម្ចាស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដឹកនាំយន្តការសម្របសម្រួល និងឆ្លើយតបជាពហុវិស័យ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវវិធានការ៦ចំណុច ដើម្បីធានាចីរភាពក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ កាលពីខែកុម្ភៈ ឆ្នាំ២០១៩នេះផងដែរ។ ពាក់ព័ន្ធនឹងកម្មវិធីមូលនិធិសកល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានទទួលតួនាទីជាអ្នកទទួលជំនួយផ្ទាល់ ចាប់តាំងពីខែមេសា ឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ននេះ។ ក្នុងភាពជាដៃគូ ដៃគូអភិវឌ្ឍន៍ដូចជាគម្រោងមូលនិធិសកល UNAIDS, USAID អង្គការសុខភាពពិភពលោក អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល បានធ្វើការរួមគ្នា ដោយត្រួតពិនិត្យនូវវឌ្ឍនភាពនៃការអនុវត្តកម្មវិធីអេដស៍។ ក្នុងការវិនិយោគ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការផ្តល់ថវិកា និងការចូលរួមយ៉ាងសកម្មក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ឯកឧត្តមបណ្ឌិត បានសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាតាពជារួកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិករឆ្ពោះបតបមេរោគអេដស៍ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា** ដែលបានលះបង់អស់កម្លាំងកាយចិត្តដោយមិនចេះនឿយហត់ក្នុងការផ្តល់ការគាំទ្រជាប់ជាប្រចាំទាំងថវិកា សម្ភារ និងស្មារតី ជួយដល់ប្រជាពលរដ្ឋក្រីក្រ អ្នករងគ្រោះទូទៅ ដោយឡែកប្រជាពលរដ្ឋដែលកំពុងរងគ្រោះដោយផ្ទាល់ និងដោយប្រយោលពីការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍នៅទូទាំងប្រទេស។

ឯកឧត្តមបណ្ឌិត សូមគោរពថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅ ចំពោះគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី មូលនិធិសកល អង្គការសង្គមស៊ីវិល ផ្នែកឯកជន សិល្បករ សិល្បការិនីដែលជាទូតសុច្ឆន្ទៈសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ បណ្តាញអ្នកផ្តុំមេរោគអេដស៍ ក្រុមប្រជាជនគន្លឹះ និងប្អូនៗជាយុវវ័យទាំងអស់ ព្រមទាំងប្រជាពលរដ្ឋទូទៅ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចបាននូវសមិទ្ធផលជាទីមោទនៈជូនប្រទេសកម្ពុជានាពេលនេះ។

ជាទីបញ្ចប់ ឯកឧត្តមបណ្ឌិតក៏បានបួងសួងទៅតាប្រទានពរជ័យមហាប្រសើរជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រៀង ម៉ុលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សូមមានសុខភាពល្អបរិបូណ៌ កម្លាំងខ្លាំងក្លា ដើម្បីបន្តរួមចំណែកដឹកនាំកម្ពុជាឱ្យចាកផុតពីគ្រោះគំរាមកំហែងដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ក្រោមមាគ៌ាដឹកនាំប្រកបដោយគតិបណ្ឌិតឈ្លាសវៃ

និងស្វាហាប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

៣.៦. អានសារលិខិត **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤ ដោយ**ឯកឧត្តមឧទេសរដ្ឋមន្ត្រី អៀង ងូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**។

ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី **ឯកឧត្តមឧទេសរដ្ឋមន្ត្រី អៀង ងូលី** បានអញ្ជើញអានទាំងស្រុងនូវសារលិខិត **សម្តេចមហាបវរធិបតី**។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចូលរួមជាមួយពិភពលោកទាំងមូលក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤ ក្រោមប្រធានបទ "**សិទ្ធិ ជាមាគ៌ាឆ្ពោះទៅបញ្ចប់អេដស៍**"។

ទិវានេះត្រូវបានប្រារព្ធឡើង ដើម្បីឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តជារួមរបស់ពិភពលោក ក៏ដូចជារាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការចូលរួមចែករំលែកនូវចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងការប្រយុទ្ធទប់ស្កាត់ការរាលដាលនៃមេរោគអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបង្ហាញពីការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នករងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យទទួលបានសេវាថែទាំ ព្យាបាល និងសេវាគាំពារសង្គម ឆ្ពោះទៅបញ្ចប់អេដស៍ឱ្យបានជាប់បំផុត។

វឌ្ឍនភាពដ៏ច្រើននៃការឆ្លើយតបនឹងមេរោគអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានផ្សារភ្ជាប់ដោយផ្ទាល់ជាមួយនឹងវឌ្ឍនភាពនៃការការពារសិទ្ធិមនុស្ស បន្ថែមលើនេះវឌ្ឍនភាពដែលសម្រេចបានក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក៏បានធ្វើឱ្យមានវឌ្ឍនភាពកាន់តែប្រសើរក្នុងការអនុវត្តសិទ្ធិនៃការទទួលបានការថែទាំសុខភាពរបស់ប្រជាជន និងការពង្រឹងប្រព័ន្ធសុខាភិបាលរបស់ប្រទេស។

ប្រទេសកម្ពុជាសម្រេចបានក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានចំណុចសំខាន់ៗដូចខាងក្រោម៖

១- នៅឆ្នាំ២០២៣កន្លងទៅនេះ ប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ថាមានអត្រាគ្របដណ្តប់សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ហួតដល់ចំនួន៩៨% នៃអ្នកដែលបានធ្វើរោគវិនិច្ឆ័យ អត្រានេះខ្ពស់ជាងគេនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

២- ចំនួននៃការឆ្លងថ្មី បានធ្លាក់ចុះពី១.៤០០នាក់ ក្នុងឆ្នាំ២០២២ មកនៅត្រឹម ១.២០០នាក់ នៅឆ្នាំ២០២៣។

៣- អ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ដែលត្រូវបានរាប់បញ្ចូលក្នុងចំណោមប្រជាជនក្រីក្រកំពុងទទួលបាននូវផលប្រយោជន៍ នៃកម្មវិធីគាំពារសង្គមកាន់តែទូលំទូលាយ។ គិតពីពេលចាប់ផ្តើមអនុវត្តកម្មវិធីក្នុងត្រីមាសទី១ ឆ្នាំ២០២២ រហូតដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២៤ មានអ្នកផ្ទុកមេរោគអេដស៍សកម្មកំពុង

ទទួលបានការព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន៤៦.២០២នាក់ (ស្មើនឹង ៦៧%) នៃ ៦៩.៤១៣នាក់ បានទទួលបណ្ណសមធម៌។

៤- ប្រទេសកម្ពុជាជាប្រទេសឈានមុខមួយ ដែលកំពុងរៀបចំកម្មវិធីអេដស៍ប្រកបដោយភាពធន់ និងចីរភាព។

៥- ប្រទេសកម្ពុជាកំពុងពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សំដៅជំរុញចន្លោជាតិមួយដ៏មុតស្រួច ដោយបង្កលក្ខណៈឱ្យគ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដំណើរការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ជាមួយនឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍ អង្គការអន្តរជាតិ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។

ជាមួយនឹងសមិទ្ធផលខាងលើ យើងទាំងអស់គ្នាត្រូវខិតខំបន្ថែមទៀត ក្នុងការស្វែងរកអ្នកផ្ទុកមេរោគអេដស៍ចំនួនប្រមាណជិត៧.០០០នាក់ ដែលមិនទាន់បានមកទទួលសេវាព្យាបាល និងខិតខំបញ្ចៀសកុំឱ្យមានការបោះបង់ ការព្យាបាលរបស់អ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ដែលកំពុងទទួលសេវាព្យាបាលថែទាំ។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវដើរតួនាទីនាំមុខ និងជាអ្នកសម្របសម្រួលកម្មវិធីបង្ការ ទប់ស្កាត់ ការរីករាលដាលនៃមេរោគអេដស៍ ដោយគ្មានការរើសអើងមាក់ងាយ និងផ្តោតការយកចិត្តទុកដាក់ ជាពិសេសចំពោះប្រជាជនគន្លឹះ រួមមានក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំផ្លែងភេទ ក្រុមអ្នកបម្រើសេវាកម្សាន្តសប្បាយ អ្នកប្រើប្រាស់គ្រឿងញៀន និងក្រុមយុវវ័យ ដែលត្រូវទាក់ទាញឱ្យមកធ្វើតេស្តរកមេរោគអេដស៍ឱ្យបានច្រើនជាទីបំផុត។ ដើម្បីឈានទៅសម្រេចជោគជ័យនៃការបង្ការ និងទប់ស្កាត់ការរីករាលដាលនេះ គ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយប្រតិបត្តិករ ព្រមទាំងជាមួយសហគមន៍នៃប្រជាជនគន្លឹះទាំងអស់ក្នុងការផ្តល់មធ្យោបាយបង្ការ និងផ្សព្វផ្សាយសារសុវត្ថិភាពនៃការរួមភេទ ដូចជាការប្រើប្រាស់ស្រោមអនាម័យ ការប្រើឱសថបង្ការមុនការប្រឈម (PrEP) ការប្រើឱសថបង្ការក្រោយការប្រឈម (PEP) និងការធ្វើតេស្តរកមេរោគអេដស៍ជាដើម។ ទន្ទឹមនឹងនេះ យើងត្រូវរួមគ្នាធ្វើយ៉ាងណាបញ្ចប់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនតាមមាគ៌ារបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំ តំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា។

"**សិទ្ធិ ជាមាគ៌ាឆ្ពោះទៅបញ្ចប់អេដស៍**" ទាមទារឱ្យប្រទេសជាសមាជិក ជាពិសេសប្រទេសកម្ពុជាធ្វើសកម្មភាពកាន់តែមានប្រសិទ្ធភាពខ្ពស់ឆ្ពោះទៅសម្រេចគោលដៅ៩៥-៩៥-៩៥នៅឆ្នាំ២០២៥ ដោយត្រូវលើកកម្ពស់គុណភាព និងស័ក្តិសិទ្ធភាពនៃសេវាព្យាបាល ថែទាំ ការធ្វើតេស្ត និងការបង្ការមេរោគអេដស៍។

ដើម្បីសម្រេចបាននូវការបញ្ចប់អេដស៍ ដែលកំពុងបន្តការគំរាមកំហែងដល់សុខភាពសាធារណៈ ក្នុងនាម**សម្តេចមហាបវរធិបតីសម្តេច** បានលើកឡើងនូវចំណុចមួយចំនួនដូចខាងក្រោម៖

ទី១- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តដឹកនាំសម្របសម្រួល និងអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ក្នុងស្មារតីបុរេសកម្ម និងទទួលខុសត្រូវខ្ពស់។

ទី២ - គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវចូលរួមគាំទ្រ និងអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ឱ្យបានសកម្មជាទីបំផុត។

ទី៣- ក្រសួងសុខាភិបាល ត្រូវពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការ ក្នុងនោះរួមមានការជំរុញការប្រើប្រាស់ស្រោមអនាម័យ កម្មវិធីប្រើឱសថបង្ការមុនការប្រឈម (PrEP) និងកម្មវិធីប្រើឱសថបង្ការក្រោយការប្រឈម (PEP)ជាដើម។

ទី៤- ក្រសួងសុខាភិបាល ត្រូវខិតខំបញ្ចូលសេវាថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍ក្នុងប្រព័ន្ធសុខាភិបាល ដោយបង្កើនទីតាំងធ្វើតេស្ត និងទីតាំងផ្តល់សេវាថែទាំព្យាបាលជំងឺអេដស៍ឱ្យបានទូលំទូលាយ និងយ៉ាងឆាប់រហ័ស។

ទី៥- ក្រសួងសុខាភិបាល ត្រូវពង្រីក ពង្រឹង និងពន្លឿនកម្មវិធីថែទាំ និងព្យាបាលឱ្យសម្រេចបាននូវស្ថានភាពរកមេរោគមិនឃើញ (Undetectable)ចំពោះអ្នកផ្ទុកមេរោគអេដស៍ ដើម្បីកាត់បន្ថយការចម្លងមេរោគអេដស៍។

ទី៦- ក្រសួងសុខាភិបាល ត្រូវសិក្សា និងចាត់វិធានការ ដើម្បីកាត់បន្ថយអត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ទន្ទឹមនឹងនេះ តាមរយៈ**សារលិខិតសម្តេចធិបតីនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី**បានអំពាវនាវដល់អង្គការដៃគូជាតិ និងអន្តរជាតិ សូមជួយគាំទ្រ ការពង្រឹងប្រព័ន្ធជាតិ តាមរយៈការបន្តផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេស ក្រោមការដឹកនាំសម្របសម្រួលរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវធ្វើការរួមគ្នាជាពហុវិស័យ សហការជិតស្និទ្ធជាមួយកាកបាទក្រហមកម្ពុជា អង្គការមិនមែន រដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន ឮ

ក្រុមអ្នកផ្ទុកមេរោគអេដស៍ ក្រុមប្រជាជនគន្លឹះ និងសហគមន៍ ដើម្បីលុបបំបាត់ការចម្លងមេរោគអេដស៍ និងយកជ័យជម្នះលើមេរោគអេដស៍ និងជំងឺអេដស៍។

ជាថ្មីម្តងទៀត សម្តេចក៏បានឧទ្ទិសខ្លឹមសារ និងអត្ថន័យនៃទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤ ក្រោមប្រធានបទ "**សិទ្ធិ** ជាមាគ៌ាឆ្ពោះទៅបញ្ចប់អេដស៍" ឆ្ពោះទៅសម្រេចគោលដៅទាំងបីដែលបានកំណត់ គឺគោលដៅទី១ កាត់បន្ថយករណីឆ្លងថ្មីនៃមេរោគអេដស៍ក្នុងរង្វង់

ចំនួនជាង២០០នាក់ក្នុងមួយឆ្នាំ គោលដៅទី២ កាត់បន្ថយអ្នកស្លាប់ដោយសារជំងឺអេដស៍មកតិចជាង ចំនួន ២០០នាក់ ក្នុងមួយឆ្នាំ និងគោលដៅទី៣ គ្មានការមាក់ងាយ រើសអើងអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។

ជាទីបញ្ចប់ ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤ ក្នុងនាម**សម្តេចធិបតីនាយករដ្ឋមន្ត្រី ឯកឧត្តមឧទេសរដ្ឋមន្ត្រី** ក៏បានថ្វាយព្រះពរ និងប្រគេនពរសម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក ព្រះថេរានុត្ថេរៈ និងជូនពរសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ក្មួយៗយុវជន យុវតី សិស្សានុសិស្ស និងបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសុក្រ ៦កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤

បានពិនិត្យ ធ្វើឯកភាពត្រឹមត្រូវ
អគ្គលេខាធិការ

បណ្ឌិត **ឈឹម ឃិនដារ៉ែត**

អ្នកធ្វើរបាយការណ៍

បណ្ឌិត **ណារិន ពិសិដ្ឋ**

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ

អៀង ងូលី